THE SCHOOL DISTRICT OF PHILADELPHIA
OFFICE OF ACADEMIC SUPPORTS

# កម្មវិធីអភិវឌ្ឍភាសាអង់គ្លេស
## លិខិតបដិសេធរបស់មាតាបិតា

ឈ្មោះសិស្ស/Student Name៖ ____________________ សាលា/Schoo៖ ____________________
កាលបរិច្ឆេទនៃការមិនចូលរួម/Opt-out Date៖ ____________________ ថ្នាក់ទី/Grade៖ __________
អត្តលេខសិស្ស/Student ID #៖ ____________________

ច្បាប់សហព័ន្ធតម្រូវឲ្យកូនរបស់លោកអ្នកប្រឡងមើលសមត្ថភាពផ្នែកភាសាអង់គ្លេស ដើម្បីឲ្យគេដឹងថាកូនរបស់លោកអ្នកមានលក្ខណៈត្រូវឲ្យគេផ្តល់កម្មវិធីអភិវឌ្ឍភាសាអង់គ្លេស (ELD) ដើម្បីអាចយល់ មេរៀនប្រចាំថ្ងៃ និង ការធ្វើទំនាក់ទំនងនៅសាលា ឬអត់។ គេបានឲ្យកូនរបស់លោកអ្នកប្រឡងភាសាអង់គ្លេស ផ្នែក ការអាន ការនិយាយ និង ការស្តាប់។ ពិន្ទុនៃការប្រឡងបានបង្ហាញថា កូនរបស់លោកអ្នកត្រូវទទួលការបង្ហាត់បង្រៀន ELD នៅក្នុងកម្មវិធីដែលគេបានរៀបចំឡើងដើម្បីជួយសិស្សឲ្យទទួលបានការស្ទាត់ជំនាញផ្នែកភាសាអង់គ្លេស និងអាចទទួលបានការបង្ហាត់បង្រៀនមេរៀនទៅតាមកម្រិតថ្នាក់។

**សិទ្ធិបដិសេធនៃការបម្រើ ELD របស់មាតាបិតា៖** សាលាបានពិពណ៌នាយ៉ាងលម្អិតអំពីកម្មវិធី ELD ដែលពួកគេបានសំណូមពរឲ្យកូនរបស់ខ្ញុំរៀន។ ខ្ញុំបានពិចារណាលើកម្មវិធីដែលផ្តល់ឲ្យដោយសាលា ហើយបានជ្រើសរើសបដិសេធការបង្រៀន ដាច់ដោយឡែក កម្មវិធីឯកទេស ELD សម្រាប់កូនរបស់ខ្ញុំ។ ការបម្រើពិសេស ឬថ្នាក់ទាំងអស់ ដែលគេផ្តល់ឲ្យសម្រាប់តែសិស្សដែលត្រូវសិក្សាភាសាអង់គ្លេស (EL) ឧទាហរណ៍ កម្មវិធី ELD ដែលដកចេញពីថ្នាក់មកបង្រៀន ការជួយបង្រៀនភាសាអង់គ្លេសដែលជាភាសាទីពីរ (ESL) ការជួយបង្រៀនភាសាអង់គ្លេសក្រោយម៉ោងសិក្សាសម្រាប់សិស្ស EL ឬ ថ្នាក់មុខវិទ្យាដែលមានតែសិស្ស EL តែប៉ុណ្ណោះ។ នេះមិនរួមបញ្ចូលថ្នាក់ដែលមានសមាសភាពសិស្ស EL និងសិស្សមិនមែន EL ដែលត្រូវបានគេជួយ ELD តាមរយៈការបង្ហាត់បង្រៀនមុខវិទ្យា នោះទេ។ ដោយការគូស (☐) ត្រង់ចំណុចនីមួយៗខាងក្រោមនេះ ខ្ញុំទទួលស្គាល់ថា ខ្ញុំបានអាន និង យល់សេចក្តីនីមួយៗ។

- ☐ ខ្ញុំដឹងអំពី ពិន្ទុនៃការវាយតម្លៃភាសាអង់គ្លេស និង ព័ត៌មានផ្សេងៗទៀតអំពីការរីកចម្រើននៃការសិក្សានាពេលបច្ចុប្បន្ន របស់កូនខ្ញុំ ហើយយល់ពីមូលហេតុដែលគេបានសំពូមពរឱ្យកូនរបស់ខ្ញុំទទួលការបង្ហាត់បង្រៀនភាសាអង់គ្លេសបន្ថែម។
- ☐ ការសម្រេចចិត្តបដិសេធ ឬ ជ្រើសរើសមិនចូលរួម កម្មវិធីឯកទេស ELD របស់ខ្ញុំ គឺដោយការស្ម័គ្រចិត្ត។
- ☐ ក្រសួងអប់រំនឹងរាយការណ៍ទៅក្រសួងអប់រំនៃរដ្ឋ ផិនស៊ីវេនីញ៉ា អំពីកូនរបស់ខ្ញុំ ថាជាសិស្សដែលត្រូវការសិក្សាភាសាអង់គ្លេស )EL) រហូតដល់កូនរបស់ខ្ញុំមានការស្ទាត់ជំនាញផ្នែកភាសាអង់គ្លេស។
- ☐ ច្បាប់របស់សហព័ន្ធតម្រូវឱ្យគេផ្តល់ការប្រឡង WIDA ACCESS សម្រាប់សិស្ស EL ២,0 ដល់កូនរបស់ខ្ញុំជារៀងរាល់ឆ្នាំ រហូតដល់គាត់មានការស្ទាត់ជំនាញផ្នែកភាសាអង់គ្លេស ហើយមិនត្រូវបានគេចាត់ទុកថាជាសិស្ស EL តទៅទៀត។
- ☐ ក្រសួងអប់រំនឹងតាមដានមើលការរីកចម្រើននៃការសិក្សារបស់កូនខ្ញុំ ដោយគ្មានការទទួលអត្ថប្រយោជន៍នៃការបម្រើពីកម្មវិធីឯកទេស ELD រហូតដល់កូនរបស់ខ្ញុំមានការស្ទាត់ជំនាញផ្នែកភាសាអង់គ្លេស និងរយៈពេល ៤ ឆ្នាំ បន្ទាប់ពីការចាកចេញពីកម្មវិធី EL។
- ☐ ក្រសួងអប់រំនឹងបន្តផ្តល់ដំណឹងដល់ខ្ញុំ អំពីការរីកចម្រើននៃការស្ទាត់ជំនាញផ្នែកភាសាអង់គ្លេសរបស់កូនខ្ញុំ។
- ☐ ខ្ញុំអាចផ្លាស់ប្តូរចិត្តរបស់ខ្ញុំបានគ្រប់ពេល ដោយការជូនដំណឹងដល់ក្រសួងអប់រំជាលាយលក្ខណ៍អក្សរ និងអនុញ្ញាតឱ្យកូនរបស់ខ្ញុំចុះឈ្មោះចូលរៀនក្នុងកម្មវិធី ELD ដែលផ្តល់ឲ្យដោយសាលា។

ខ្ញុំ ____________________ឈ្មោះ) មាតាបិតាអា/ណាព្យាបាល (យល់អំពីព័ត៌មានខាងលើនេះទាំងស្រុង ហើយមានបំណងចង់

- ☐ បដិសេធ កម្មវិធី និង ការបម្រើ កម្មវិធីឯកទេស ELD **ទាំងអស់** ដែលគេចង់ផ្តល់ឲ្យកូនរបស់ខ្ញុំ។
- ☐ បដិសេធ កម្មវិធីឯកទេស ELD និងឬ/ ការបម្រើ ELD **មួយចំនួន** ដែលគេចង់ផ្តល់ឲ្យកូនរបស់ខ្ញុំ។

ហត្ថលេខារបស់ មាតាបិតា/អាណាព្យាបាល/Parent/Guardian Signature៖ ____________________ ថ្ងៃខែ/Date៖ ____________________